**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

# ញត្តិថ្កោលទោស

# សកម្មភាពឈ្លានពានរបស់យោធាថៃ លើបូរណភាពទឹកដី អធិបតេយ្យភាពរបស់កម្ពុជា

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមបន្តថ្កោលទោសយ៉ាងដាច់អហង្ការចំពោះរដ្ឋាភិបាល និងយោធាថៃ ដែលកាន់តែពង្រីកសកម្មភាពឈ្លានពានលើបូរណភាពទឹកដីអធិបតេយ្យភាពរបស់កម្ពុជា ដែលគិតចាប់ពីថ្ងៃទី៧ រហូតមកដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥នេះ សកម្មភាពបាញ់ផ្លោងទម្លាក់គ្រាប់គ្រប់ប្រភេទ គ្រប់ទម្រង់ទាំងជើងគោក ជើងអាកាស និងជើងទឹក ជាពិសេសការទម្លាក់គ្រាប់បែកពីយន្តហោះF-16 និងT-50TH នៅតាមតំបន់ជាច្រើនតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងចូលជ្រៅមកក្នុងប្រទេសកម្ពុជាជាង៩០គីឡូម៉ែត្រពីព្រំដែន បណ្តាលឱ្យប្រជាជនស៊ីវិលស្លូតត្រង់បាត់បង់ជីវិត៣០នាក់ និងរងរបួស៨៧នាក់ រីឯជនភៀសសឹកបានកើនឡើងរហូតដល់ជាង៦៣ម៉ឺននាក់ ក្នុងនោះស្ត្រីនិងកុមារ មានចំនួនជាង៥០%។

សកម្មភាពឈ្លានពានរបស់ថៃ ដោយការប្រើប្រាស់យន្តហោះF-16 និងT-50TH ទម្លាក់គ្រាប់បែកគ្រប់ទីកន្លែងបំផ្លាញដោយអគតិមកលើលំនៅដ្ឋានប្រជាជន វត្តអារាម ហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និងតំបន់បេតិកភណ្ឌ (ប្រាសាទព្រះវិហារទទួលរងការខូចខាតធ្ងន់ធ្ងរ រីឯប្រាសាទតាក្របីត្រូវបានបំផ្លាញទាំងស្រុង) គឺជាទង្វើដ៏ព្រៃផ្សៃ និងរំលោភបំពានដល់សិទ្ធិមនុស្ស ច្បាប់អន្តរជាតិ ដោយរួមទាំងអនុសញ្ញានានា ស្តីពីកិច្ចការពារបេតិកភណ្ឌផងដែរ។ យោធាថៃបានបន្តបាញ់បំផ្លាញប្រាសាទព្រះវិហារ និងបានបន្តប្រើប្រាស់យន្តហោះF-16 បំផ្លាញទីតាំងជាច្រើន ដោយក្នុងនោះបណ្តាលឱ្យស្ពានបុរាណ (ស្ពានទ័ព) នៅស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ដែលបុរាណស្ថាននេះស្ថិតនៅចម្ងាយជាង៧០គីឡូម៉ែត្រពីព្រំដែន ទទួលរងការខូចខាត និងកំពុងប្រឈមហានិភ័យខ្ពស់។ ការវាយបំផ្លាញបដិមាតំណាងព្រះនារាយណ៍ និងរូបសំណាក តា អ៊ុំ នៅតំបន់អានសេះ ខេត្តព្រះវិហារ ដែលជាបដិមាសម្រាប់ការគោរពបូជា គឺជាទង្វើគ្មានសីលធម៌ គ្មានសាសនា ដែលបញ្ជាក់ច្បាស់អំពីការយកវប្បធម៌ ជំនឿសាសនា ជាសត្រូវរបស់ខ្លួន។

យើងខ្ញុំទាំងអស់គ្នាសូមអំពាវនាវដល់គ្រប់បណ្តាប្រទេសទាំងអស់ ដែលជារដ្ឋភាគីនៃអនុសញ្ញាឆ្នាំ១៩៥៤ និង១៩៧២ និងបណ្តាសហគមន៍អន្តរជាតិ ចូលរួមថ្កោលទោសចំពោះសកម្មភាពឈ្លានពានដោយកំរោលរបស់យោធាថៃមកលើបូរណភាពទឹកដី អធិបតេយ្យភាពកម្ពុជា និងជួយជ្រោមជ្រែងជំរុញឱ្យភាគីថៃបញ្ឈប់សកម្មភាពឈ្លានពានសកម្មភាពបំផ្លិចបំផ្លាញបេតិកភណ្ឌកម្ពុជា និងងាកមករកដំណោះស្រាយដោយសន្តិវិធីតាមរយៈការគោរពសេចក្តីប្រកាសរួមទីក្រុងកូឡាឡាំពួរ។

យើងខ្ញុំក៏សូមប្តេជ្ញាបន្តគាំទ្រដោយឥតងាករេរាល់វិធានការ និងការសម្រេចចិត្តប្រកបដោយភាពចាស់ទុំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយជម្លោះព្រំដែន ដោយសន្តិវិធី និងការការពារបូរណភាពទឹកដី អធិបតេយ្យភាពព្រមទាំងអាយុជីវិតដ៏ថ្លៃថ្លារបស់ប្រជាពលរដ្ឋកម្ពុជាដ៏ស្លូតត្រង់៕

ថ្ងៃព្រហស្បតិ៍ ៦កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥

ទូរសព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ